# មេរៀនទី ៩៩៖ កំហុសដ៏ធំបំផុតរបស់សូល

## ១ សាំយូអែល ១៣៖១-១៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/ObgaYD-8T30

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/AQAGIPJh4Vk

**គោលបំណង៖** ផ្លូវរបស់ព្រះគឺពិតជាសំខាន់ណាស់។

**ខគម្ពីរចងចាំ៖** សុភាសិត ១៤៖១២ *“មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្ដីស្លាប់វិញ។”*

**ចំរៀង** ( *យូធូបលីង* )៖

១. ចូរប្រយ័ត្ននឹងភ្នែកតូចៗអ្នក https://youtu.be/leoAGL9usF0

២. ខ្ញុំដឹងខ្លួនហើយ https://youtu.be/cNotISrjHI0

៣. ខ្ញុំសូមលើកព្រះនាមទ្រង់ឡើង https://youtu.be/rPE5QOHbo70

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត “ត្រពាំងឬស្សី”



១. ឲ្យកុមារឈរតាមជួរនីមួយៗ ៣ឬ៤ជួរ

២. នៅពេលដែលគ្រូនិយាយថា“ឫស្សី” កុមារទាំងអស់ត្រូវក្រោកឈរ។ នៅពេលដែលគ្រូនិយាយថា “ទំពាំង” កុមារទាំងអស់ត្រូវអង្គុយចុះ។ តោះសូមចាប់ផ្ដើមលេង។

៣.ដើម្បីបន្លំដល់កុមារគ្រូត្រូវធ្វើកាយវិការផ្ទុយពីអ្វីដែលគ្រូនិយាយ។ ឧទាហរណ៍៖ គ្រូស្រែកថា “ឫស្សី” ហើយអង្គុយចុះ។ ប្រសិនបើកុមារធ្វើតាមគ្រូដោយអង្គុយចុះដែរ នោះកុមារនឹងចាញ់ល្បែងនេះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា អ្នកដែលចាញ់ល្បែងនេះ ដោយសារតែគាត់មិនបានយកចិត្តទុកដាក់ពីអ្វីដែលគាត់បាននិយាយ។ ការស្ដាប់តាមព្រះគឺពិតជាមានសារៈសំខាន់ណាស់។

### ៤. ការណែនាំមេរៀន

នៅពេលដែលអ្នកមានបញ្ហា តើអ្នកចង់ដោះស្រាយបញ្ហានោះតាមផ្លូវរបស់អ្នក ឬក៏អ្នកចង់ដោះស្រាយបញ្ហានោះដោយដើរតាមផ្លូវរបស់ព្រះ? ជាការពិតណាស់ យើងច្បាស់ជាចង់ដើរតាមផ្លូវរបស់ព្រះ ពីព្រោះថា ព្រះទ្រង់ស្រលាញ់យើង ហើយស្គាល់យើង ទ្រង់ជ្រាបដឹងពីអ្វីដែលល្អបំផុតសម្រាប់យើង។ ប៉ុន្តែ តើមានអ្វីកើតឡើង ប្រសិនបើព្រះប្រើពេលដ៏យូរក្នុងការជួយយើងនោះ? តើយើងគួរតែបំភ្លេចព្រះចោលហើយដោះស្រាយបញ្ហានោះដោយខ្លួនឯងឬយ៉ាងណា? ឬក៏ តើយើងគួរតែចាំព្រះបន្តិចសិន ពីព្រោះថាផ្លូវរបស់ទ្រង់គឺសំខាន់? ថ្ងៃនេះ យើងនឹងរៀនអំពីបញ្ហារបស់សូល ដែលជាស្ដេចថ្មីរបស់សាសន៍អ៊ីស្រាអែល។ តើអ្នកគិតថា គាត់ព្យាយាមដោះស្រាយបញ្ហាដោយប្រាជ្ញារបស់គាត់ឬក៏តាមផ្លូវរបស់ព្រះ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ឥឡូវនេះពួកអ៊ីស្រាអែលមានស្តេចថ្មីដែលមានឈ្មោះថា សូល។ ជនជាតិអ៊ីស្រាអែលត្រេកអរជាខ្លាំង ដែលពួកគេមានស្តេចខាងសាច់ឈាមជាអ្នកគ្រប់គ្រងលើពួកគេ។ ស្តេចសូល កំពុងប្រឈមមុខនឹងសង្គ្រាមដ៏ធំមួយជាមួយពួកភីលីស្ទីន ហើយគាត់ត្រូវការកម្លាំងមកពីព្រះ ដើម្បីបំពេញគាត់នឹងទាហានរបស់គាត់ ក្នុងការដណ្តើមយកជ័យជំនះ។ ហោរាសាំយូអែល បានប្រាប់ស្តេចឲ្យធ្វើការរងចាំរយៈពេលប្រាំពីរថ្ងៃនៅត្រង់គីលកាល គឺជាពេលដែលហោរាសាំយូអែលត្រូវមក ដើម្បីថ្វាយដង្វាយដុតទៅកាន់ព្រះសម្រាប់សង្គ្រាមនេះ។ ព្រះចង់ឲ្យសាំយូអែលធ្វើការដឹកនាំមនុស្សគ្រប់គ្នាថ្វាយបង្គំ មុននឹងសង្គ្រាមចាប់ផ្តើម។

ក្នុងកំឡុងពេលរងចាំហោរាសាំយូអែលមក កងទ័ពរបស់សូលបានលាក់ខ្លួននៅក្នុងគុម្ពព្រៃ ក្នុងរូងភ្នំ និងក្រោយផ្ទាំងថ្មធំៗ ពីព្រោះពួកគេមានការភ័យខ្លាចនឹងពួកភីលីស្ទីន។ សូលរងចាំថ្ងៃបន្ទាប់ទៀត។ សូលបានធ្វើការរងចាំ ថ្ងៃទីបី ទីបួន។ ហើយកងទ័ពរបស់គាត់មានការភ័យញាប់ញ័រជារៀងរាល់ថ្ងៃ។

គាត់ធ្វើការរងចាំរយៈពេល ប្រាំមួយទៅ ប្រាំពីរថ្ងៃ។ រួចទាហានរបស់គាត់ចាប់ផ្តើមរត់ចោលជួរ។ ហើយហោរាសាំយូអែលនៅតែមិនទាន់មកទៀត! នៅថ្ងៃទីប្រាំពីរ សូលទ្រាំមិនបានក្នុងការរងចាំហោរាសាំយូអែលមកដើម្បីថ្វាយដង្វាយដុតទៅព្រះ។ គាត់គិតថា "យើងគួរតែថ្វាយដង្វាយដុតទៅកាន់ព្រះជាម្ចាស់ ដោយខ្លួនឯង។ យើងមិនអាចធ្វើតាមអ្វីដែលព្រះមានបន្ទូលមកកាន់យើងនោះទេ ព្រោះថាទាហានរបស់ យើងរត់ចោលយើងជិតអស់ហើយ ហើយទាហានរបស់ភីលីស្ទីននឹងមកវាយយើងគ្រប់ពេលទាំងអស់ ចំណែកឯសាំយូអែលមិនឃើញមកសោះ"។ ដូច្នេះ សូលក៏សម្រេចចិត្តថ្វាយដង្វាយដុតទៅព្រះ ដោយខ្លួនឯងជំនួសឲ្យការរងចាំហោរាសាំយូអែលនូវអ្វីដែលព្រះបានប្រាប់គាត់ឲ្យធ្វើ! សូលមិនមានការអត់ធ្មត់នោះទេ ហើយគាត់ក៏សម្រេចចិត្តធ្វើអ្វីៗតាមផ្លូវរបស់គាត់ ជំនួសឲ្យការរងចាំផ្លូវដែលព្រះបានបង្ហាញគាត់ឲ្យធ្វើ។

សាំយូអែលបានបង្ហាញខ្លួន នៅពេលដែលសូលថ្វាយដង្វាយទៅកាន់ព្រះរួច។ សាំយូអែលខឹងណាស់។ ហើយព្រះក៏ខ្វាល់ដែរ។ ព្រះបានមានបន្ទូលថា ទ្រង់នឹងមិនឲ្យសូលបន្តធ្វើជាស្តេចទៀតឡើយ ហើយថាទ្រង់នឹងជ្រើសរើសស្តេចថ្មីមួយអង្គទៀត។ នេះមានន័យថា កូនប្រុសរបស់គាត់នឹងមិនអាចក្លាយទៅជាស្តេចបន្ទាប់ របស់សាសន៍អ៊ីស្រាអែលទៀតនោះឡើយ។ សូលបានគិតថា ផ្លូវរបស់គាត់ល្អជាងការរង់ចាំព្រះ ប៉ុន្តែព្រះតែងតែចង់ឲ្យយើងដឹងថា ផ្លូវរបស់ព្រះគឺល្អជាង — ទោះបីជាយើងត្រូវរង់ចាំយូរប៉ុនណាក៏ដោយ។

ផលវិបាកនៃការមិនធ្វើតាមការបង្ហាញផ្លូវរបស់ព្រះ នៅពេលដែលពេលវេលាមកដល់វាអាចក្លាយទៅជារឿងអាក្រក់សម្រាប់យើង។ រាល់ពេលដែលយើងមិនធ្វើតាមផ្លូវរបស់ព្រះ យើងកំពុងបង្ហាញប្រាប់ព្រះថាផ្លូវរបស់ទ្រង់មិនមានសារៈសំខាន់នោះទេ។ នោះជាអ្វីដែលសូលបានធ្វើ។ កុំធ្វើដូចសូលឲ្យសោះ! ចូរយើងជ្រើសរើសស្រឡាញ់ព្រះ ហើយស្តាប់បង្គាប់ទ្រង់ ព្រោះផ្លូវរបស់ព្រះអង្គគឺសំខាន់។

## ៦. សំនួរពិភាក្សា

១. តើសូលត្រូវធ្វើសង្គ្រាមជាមួយអ្នកណា? *(ភីលីស្ទីន)*

២. តើសូលនិងកងទ័ពរបស់គាត់មានទំនុកចិត្តក្នុងការយកឈ្នះច្បាំងនឹងពួកភីលីស្ទីនដែរឬទេ? *(ទេ)*

៣. តើពួកគេកំពុងរង់ចាំនរណានៅគីលកាល់ ហើយដើម្បីអ្វី? *(ពួកគេកំពុងរង់ចាំសាំយូអែលថ្វាយដង្វាយដុតដល់ព្រះ ដើម្បីផ្តល់អំណាចដល់ពួកគេដើម្បីឈ្នះការប្រយុទ្ធនឹងពួកភីលីស្ទីន )*

៤. តើស្ដេចសូលបានធ្វើអ្វីខ្លះ? *(ជំនួសឲ្យការរង់ចាំហោរាសាំយូអែល នោះសូលបានថ្វាយយជ្ញាយដុតដល់ព្រះដោយខ្លួនឯង ព្រោះគាត់ភ័យខ្លាច ហើយមិនទុកចិត្តព្រះ)*
៥. តើអ្វីជាលទ្ធផលនៃការមិនស្ដាប់បង្គាប់របស់ស្ដេចសូល? *(ព្រះនឹងជ្រើសរើសស្ដេចថ្មីបន្ទាប់ពីគាត់ ដូច្នេះ កូនរបស់សូលនឹងមិនធ្វើជាស្ដេចបន្ទាប់ទៀតទេ)*

## ៧. ល្បែងកំសាន្ត «ស្ដាប់អោយជាក់»

សម្ភារៈដែលត្រូវការ៖ ក្រដាសវិញ្ញាសារ "ជិះម៉ូតូ" "ជិះកង់" ឬក៏ "ជិះសេះ"



១. ចែកកុមារជា៤ក្រុម ហើយជ្រើសរើសមេក្រុមម្នាក់ ១
២. ឲ្យមេក្រុមទាំងបួនទៅទទួលវិញ្ញាសារពីគ្រូ
៣. ហើយគ្រូក៏បង្ហាញក្រដាសវិញ្ញាសារ ដល់មេក្រុមទាំងបួន "ជិះម៉ូតូ" "ជិះកង់" ឬក៏ "ជិះសេះ"។
៤. មេក្រុមក៏ត្រឡប់ទៅវិញ ហើយធ្វើកាយវិការបង្ហាញទៅកូនក្រុមដែលឈរបែរខ្នង។ មេក្រុមក៏ប៉ះស្មាអ្នកនៅក្រោយគេនោះ ហើយព្យាយាមប្រាប់កុមារនោះដោយធ្វើកាយវិការ។
៥. កុមារដែលនៅក្រោយគេនឹងធ្វើការទាយថា កាយវិការនោះជាអ្វី។ ក្រុមណាដែលទាយត្រូវ នឹងឈ្នះល្បែងនេះ។
៦. ក្រុមដែលឈ្នះនឹងច្រៀងចម្រៀងឲ្យក្រុមដែលចាញ់រាំ ឬក៏ដើរដំណើរទា។
៧. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ប្រសិនបើយើងធ្វើបានល្អត្រឹមត្រូវតាមអ្នកដឹកនាំនោះយើងនឹងឈ្នះល្បែងនេះ។ ក៏ដូចគ្នានេះដែរ ប្រសិនបើយើងធ្វើតាមព្រះដែលជាអ្នកដឹកនាំរបស់យើង នោះយើងនឹងទទួលបានភាពជោគជ័យនៅក្នុងជីវិតរស់នៅ។

## ៨. ខគម្ពីរចងចាំ

***សុភាសិត ១៤៖១២*** *"មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្ដីស្លាប់វិញ។"*

## ៩. ហត្ថកម្ម «ខ្ញុំនឹងដើរតាមផ្លូវរបស់ព្រះ»



សម្ភារៈដែលត្រូវការ៖ បោះពុម្ពរូបស្បែកជើង ខ្មៅដៃពណ៌ និងកន្ត្រៃ



១. បោះពុម្ពរូបស្បែកជើងសម្រាប់កុមារគ្រប់ៗគ្នា។
២. ឲ្យកុមារធ្វើការតុបតែងរូបជើង។
៣. ឲ្យកុមារកាត់រូបជើងចេញមកហើយកាត់ផ្នែករង្វង់មូលកណ្ដាលចេញផង។
៤. សូមឲ្យកុមារពាក់ស្បែកជើង (មើលរូបភាព) ហើយនិយាយថា "ខ្ញុំនឹងដើរតាមព្រះ ព្រោះផ្លូវរបស់ព្រះគឺសំខាន់!"

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖** (**សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន**)
វាពិតជាងាយក្នុងការព្រួយបារម្ភ និងភ័យខ្លាចនៅពេលដែលអ្វីៗ មើលទៅហាក់ដូចជាកំពុងដើរតាមផ្លូវរបស់ពួកគេ ប៉ុន្តែដោយសារតែយើងមានព្រះយេស៊ូវនៅក្នុងជីវិតរបស់យើង យើងមិនចាំបាច់ភ័យខ្លាចទេ! សូម្បីតែបន្ទាប់ពីព្រះបានតាំងសូលជាស្តេចអ៊ីស្រាអែលក៏ដោយ សូលមិនបានទុកចិត្តព្រះយ៉ាងពិតប្រាកដឡើយ។ តើជីវិតរបស់អ្នកបង្ហាញពីជំនឿដែលអ្នកមានបានល្អប៉ុណ្ណា? តើការទុកចិត្តរបស់អ្នកធ្លាក់ចុះក្នុងផ្នែកណាខ្លះ? ការទុកចិត្តលើព្រះមិនមែនជាបញ្ហានៃការនិយាយពាក្យត្រឹមត្រូវនោះទេ។ វាជាការបង្ហាញការទុកចិត្តតាមរយៈសកម្មភាពរបស់យើង។

# ខ្ញុំនឹងដើរតាមផ្លូវរបស់ព្រះ!"

